ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៦៣ **តាងនាមប្រជារាស្ត្រខ្មែរ**

ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០០ **តុលាការកំពូល**

សាលដីកា

លេខ : ១៨

ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០២

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១- ឯកឧត្តម **ឃឹម ប៊ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក ជីវ កេង ចៅក្រម

៤- លោក ប្រាក់ គីមសាន ចៅក្រមរបាយការណ៍

៥- លោក វៀល មួន ចៅក្រម

ក្រឡាបញ្ជី

លោក សុខ ប៊ុនសង

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៨៨ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៦៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០០ របស់តុលាការកំពូល ។

<u>ពីបទ</u> : បង្ករបួសស្នាមចេដាយចេតនាមានអាវុធ ប្រព្រឹត្តនៅភូមិថ្នល់បែក ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ ។

- ជនជាប់ចោទឈ្មោះចេង សុន "ចុងបណ្តឹងសាទុក" ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើតនិងរស់នៅសព្វថ្ងៃភូមិព្រៃព្រាល ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ ឪពុកឈ្មោះឆាយ ចេង "ស្លាប់" ម្តាយឈ្មោះចក់ សឹង "រស់" ប្តីឈ្មោះយ៉ង សន មានកូន០៨នាក់ ។

- មេធាវី គ្មាន

- ដើមបណ្តឹងរដ្ឋប្បវេណី និង ជនរងគ្រោះឈ្មោះប៉ោ ដាណេ ( ម្ចាស់បណ្តឹងសាទុក្ខ ) ភេទស្រី អាយុ ៣៣ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិថ្នល់បែក ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

- មេធាវីគ្មាន

តាមពាក្យបណ្តឹងរបស់ឈ្មោះប៉ោ ដាណេ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៧ ប្តឹងពីឈ្មោះចេង សន អាយុ៥៥ឆ្នាំ ភេទស្រី និង ឈ្មោះស៊ន ៣ ភេទប្រុស នៅភូមិព្រៃព្រាល ឃុំត្រពាំងឫស្សី បានព្រួតគ្នាវាយខ្លួនដល់ផ្ទះ ដោយយកដុំថ្ម និង ដីខ្សាច់គប់មកលើមុខខ្លួន រួចចាប់បោចសក់កាច់កបោកទៅដី និង ធ្វើអោយបាត់ក្រវិលខ្លួនមួយចំហៀងទំងន់៧ហ៊ុន ខ្លួនប្តឹងសុំជួយរកយុត្តិធម៌ផង ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តបាត់ដំបងថា : មានពិរុទ្ធគ្រប់គ្រាន់ លើជនជាប់ចោទឈ្មោះចេង សន អយ្យការរក្សាបទចោទដដែល ទៅតាមមាត្រា៤១នៃច្បាប់ព្រហ្មទណ្ឌអន្តកាល សូមតុលាការវិនិច្ឆ័យសេចក្តីទៅតាមច្បាប់ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៣ ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ធំ ដែលបានសំរេច :

១-ផ្តន្ទាទោសឈ្មោះចេង សន ដាក់ពន្ធនាគារចំនួន១ឆ្នាំ តែទោសនេះត្រូវព្យួរតាមមាត្រា៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ពីបទ : បង្ករបួសស្នាមដោយចេតនាមានអវុធ ប្រព្រឹត្តនៅភូមិថ្នល់បែក ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី២១ ខែមីនាឆ្នាំ១៩៩៧ តាមបញ្ញត្តិមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ទោសខាងលើនេះគិតចាប់តាំងពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

២-វត្ថុតាងមានដើមស្រួលប្រវែង២ម ចំនួន១ដើម មានបោះដែកគោល២ ត្រូវរឹបអូស និង បំផ្លាញចោល ។

៣-អោយឈ្មោះចេង សន ជូសជុលសំណង និង ជំងឺចិត្តជាប្រាក់៥០០ដុល្លាអាមេរិក ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះប៉ោ ដាណេ ។ បណ្តឹងលើសពីនេះត្រូវលើកចោល បើឈ្មោះចេង សន មិនសងប្រាក់ទេ ត្រូវអនុវត្តនីតាមមាត្រា៧ នៃច្បាប់ដាក់គុកបង្ខំរូបកាយដើម្បីទារប្រាក់ធនទណ្ឌក្នុងរឿងព្រហ្មទណ្ឌ ។

៤-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូភាគី បើភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ១០ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩៨ របស់ឈ្មោះចេង សន ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៣ ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ធំ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : ចំពោះការចោទប្រកាន់របស់តុលាការខេត្តកំពង់ធំ ពិតជាត្រឹមត្រូវហើយ ចំណែកសំណងពុំមានភស្តុតាងបញ្ជាក់ថា : ព្យាបាលអស់៥០០ដុល្លាទេ សូមក្រុមប្រឹក្សាពិចារណា និង សំរេច ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៨៨ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩៨ របស់ឈ្មោះចេង សន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ធំទុកជាបានការ ប៉ុន្តែលើកលែងចំណុចទី៣ ត្រូវកែប្រែសំណងថ្លៃថ្នាំព្យាបាល និងជំងឺចិត្តពី៥០០ដុល្លាអាមេរិក មកនៅត្រឹម៥០០.០០០រ០០ (ហាសិបម៉ឺនរៀល) ចំណុចផ្សេងពីនេះរក្សាទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះចេង សន ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះប៉ៅ ដាណេ កំបាំងមុខជនជាប់ចោទ ឈ្មោះ ស៊ន ៣ ។

-បានឃើញបណ្តឹងសាទុក្ខលេខ២៨ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០ របស់អ្នកស្រីប៉ៅ ដាណេ បានប្តឹងមិនសុខចិត្ត និងសាលដីកាលេខ៨៨ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- អ្នកស្រីប៉ៅ ដាណេ បានទទួលលិខិតបង្គាប់អោយធ្វើសារណាហើយ ប៉ុន្តែពុំបានធ្វើសារណាជូនមកតុលាការកំពូលឡើយ ។

- បានស្តាប់របាយការណ៍ ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ ថា : ឈ្មោះចេង សន ពិតជាបានបង្ករបួសស្នាមលើជនរងគ្រោះប្រាកដមែន ។

+តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨៨ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះប៉ៅ ដាណេ (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលសវនាការថា : នាងខ្ញុំឱ្យតុលាការកំពូលជួយរកយុត្តិធម៌ ព្រោះនាងខ្ញុំត្រូវរបួសជាទម្ងន់ ដែលបានព្យាបាលអស់រយៈពេលជាយូរ និង ត្រូវចំណាយថវិការអស់ជាច្រើន បែរជាសាលាឧទ្ធរណ៍សំរេចឱ្យសំណងនាងខ្ញុំតិចណាស់ គឺខុសឆ្ងាយពីសំណងនៅតុលាការខេត្តកំពង់ធំ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ ថា :សូមឱ្យតុលាការតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកពេញទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៨ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០ របស់អ្នកស្រីប៉ៅ ដាណេ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា អ្នកស្រីប៉ៅ ដាណេ ពុំបានប្តឹងឧទ្ធរណ៍ពីសាលក្រមរបស់តុលាការខេត្តកំពង់ធំទេ ដូច្នេះបណ្តឹងសាទុក្ខរបស់អ្នកស្រីរូបនេះ ប៉ះពាល់តែលើរឿងសំណងជំងឺចិត្តប៉ុណ្ណោះ ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ស្ថានភាពរបួសរបស់ជនរងគ្រោះពុំមានលក្ខណៈធ្ងន់ធ្ងរឡើយ ដូច្នេះការដែលសាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

- យល់ឃើញថា ដោយម្ចាស់បណ្តឹងសាទុក្ខ ជាដើមបណ្តឹងរដ្ឋប្បវេណីបានទទួលលិខិតបង្គាប់ឱ្យធ្វើសារណាការពារខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានធ្វើសារណាការពារខ្លួនជូនមកតុលាការកំពូលទេ ដូច្នេះជនជាប់ចោទក៏ពុំមានសារណាតប ហើយក៏ពុំបានមកចូលរួមសវនាការនេះដែរ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៨៨ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលសំរេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី**

**កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ២៨ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០ របស់អ្នកស្រីប៉ោ ដាណេ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨៨ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០២ ។